**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2012, 15:03
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឲ្យជនជាប់ចោទត្រូវមានវត្តមាន ដើម្បីស្ដាប់ការចោទប្រកាន់ និងសេចក្ដីសន្និដ្ឋានបើកការចោទប្រកាន់**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Motoo NOCGHUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម ស៊ិន វិទ្ធ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម យ៉ា ណារិន

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្ដម
លោក Michael G.KARNAVAS

| | |
|---|---|
| ពេជ អង្គ | លោក គង់ សំអុន |
| Elisabeth SIMONNEAU FORT | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |

# ចម្លើយតប

១. នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តី អៀង សារី ("សហមេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខមួយ[1] ជូនអង្គជំនុំជម្រះតុលាការកំពូល("អង្គជំនុំជម្រះ") ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធចំនួនពីរ របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងអម្លុងពេលនៃកិច្ចដំណើរការសវនាការ នៅថ្ងៃទី២១ និង២២ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលតម្រូវឲ្យ អៀង សារី នៅតែបង្ហាញវត្តមានក្នុងសាលសវនាការ ក្នុងអម្លុងសវនាការនៃសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ("សេចក្តីសម្រេចដែលរងការជំទាស់")[2]។ គូភាគីត្រូវបានគេជូនដំណឹងតាមរយៈបណ្តឹងឧទ្ធរណ៍នេះធ្វើឡើងជាភាសាខ្មែរ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ និងជាភាសាអង់គ្លេស នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២។ អនុលោមតាមសេចក្តីណែនាំអនុវត្ត មាត្រា៨.៣ និង៨.៥[3] ចម្លើយតបនេះត្រូវបានដាក់ក្នុងចិរវេលាដូចបានចែងកំណត់ ដោយគិតចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ បន្តមក។

២. សហមេធាវីការពារក្តីសំអាងទៅលើ វិធាន១០៤(១), ១០៤(៤)(ឃ) និង ១០៥(២) នៃវិធានផ្ទៃក្នុង ដើម្បីជាមូលដ្ឋានសម្រាប់ឲ្យមានការទទួលយកបណ្តឹងសាទុក្ខបន្ទាន់នេះ[4]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាបណ្តឹងសាទុក្ខនេះ គឺជាក់ស្តែងណាស់ថា មិនអាចទទួលយកបាននៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ដោយផ្អែកលើមូលដ្ឋាននេះ និងដើម្បីជាការផលប្រយោជន៍នៃការសន្សំសំចៃរបស់តុលាការ សហព្រះរាជអាជ្ញានឹងដាក់កម្រិតទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួននេះត្រឹមតែអំពីយុត្តាធិការ និងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះតែប៉ុណ្ណោះ។

*តាមវិធាន១០៤(១) គេគ្មានមូលដ្ឋានផ្លូវច្បាប់សម្រាប់ឲ្យមានការទទួលយកបណ្តឹងសាទុក្ខនេះទេ*

៣. ដំបូង សហមេធាវីការពារក្តីអះអាងថា បណ្តឹងសាទុក្ខបន្ទាន់មួយអាចធ្វើទៅបានដោយហេតុថាសេចក្តីសម្រេចដែលរងការជំទាស់នេះគឺ "ជាការរំលោភបំពានមួយទៅលើឆន្ទានុសិទ្ធិ ដែលនាំឲ្យមានបុរេនិច្ឆ័យ..."[5]។ អំណះអំណាងនេះ គឺជាការអានដោយយល់ច្រឡំអំពីយុត្តាធិការរបស់អង្គជំនុំជម្រះ ដែលមានទៅលើបណ្តឹងសាទុក្ខភ្លាមៗ។ វិធាន ១០៤(១) គឺជាបញ្ញត្តិទូទៅមួយដែលបានចែងកំណត់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះទៅលើបណ្តឹងសាទុក្ខទាំងអស់ រួមទាំងបណ្តឹងសាទុក្ខ

---

[1] **E130/4/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអម្លុងពេលជំនុំជម្រះក្តី និងក្នុងការទទួលបានការជួយការការពារក្តីរបស់គាត់ដោយខ្លួនឯង, ៥ មករា ២០១២ ("បណ្តឹងសាទុក្ខ")។

[2] **E1/13.1** ប្រតិចារិក, ២១ វិច្ឆិកា ២០១១ ត្រង់ទំព័រទី៣៦-៣៧។ **E1/14.1** ប្រតិចារិក, ២២ វិច្ឆិកា ២០១១ ត្រង់ទំព័រទី៨។

[3] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៧; ការដាក់ឯកសារនៅ អ.វ.ត.ក។

[4] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សំគាល់ *ខាងដើម* លេខ១ ត្រង់កថាខ័ណ្ឌទី៦។

[5] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សំគាល់ *ខាងដើម* លេខ១ ត្រង់កថាខ័ណ្ឌទី៧។

ភ្លាមៗ។ អង្គជំនុំជម្រះកន្លងមកធ្លាប់បានសម្រេចថា យុត្តាធិការរបស់ខ្លួនទៅលើបណ្តឹងសាទុក្ខភ្លាមៗ គឺត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងត្រឹមតែមូលដ្ឋានទាំងឡាយដែលមានចែងក្នុង វិធាន១០៤(៤) តែប៉ុណ្ណោះ[6]។

៤. និយមន័យធម្មតាតាមវិធានផ្ទៃក្នុង ដូចដែលអង្គជំនុំជម្រះបានអនុវត្ត គេបើកផ្លូវឲ្យធ្វើបណ្តឹងសាទុក្ខ *ភ្លាមៗ* បានតែនៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចំនួនបួនប្រភេទជាក់លាក់តែប៉ុណ្ណោះគឺៈ (i) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី, (ii) សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមវិធាន៨២, (iii) សេចក្តីសម្រេចអំពីវិធានការការពារ តាមវិធាន២៩(៤)(គ) និង (iv) សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន៣៥(៦)[7]។ សេចក្តីសម្រេចផ្សេងៗទៀតទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង "អាចប្តឹងសាទុក្ខបានតែក្នុងករណី ដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខ ពីសាលក្រមលើអង្គសេចក្តី" ប៉ុណ្ណោះ[8]។

៥. សំអាងហេតុរបស់សហមេធាវីការពារក្តី បើត្រូវបានទទួលយក មុខជាត្រូវបានអនុញ្ញាតឲ្យមានដំណោះស្រាយជាបណ្តឹងសាទុក្ខភ្លាមៗ ទៅនឹងការលើកឡើងចោទប្រកាន់ពីការបំពានលើឆន្ទានុសិទ្ធិរបស់តុលាការ ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងបរិបទណាមួយក៏ដោយ។ លទ្ធផលបែបនេះមិនអាចត្រូវបានទ្រទ្រង់ដោយ និយមន័យធម្មតាតាមវិធានផ្ទៃក្នុង បាននោះទេ ហើយវាផ្ទុយទៅនឹង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[9] ក្រមនីតិវិធីព្រហ្មទណ្ឌនៃយុត្តាធិការច្បាប់ស៊ីវិលនានា[10] និងការអនុវត្តជាអន្តរជាតិ[11] ទៀតផង។ នៅក្នុងករណីទាំងអស់នេះ យុត្តាធិការលើបណ្តឹងសាទុក្ខភ្លាមៗ (ឬ "បន្ទាន់បន្ទំ") ត្រូវបានគេកម្រិតយ៉ាងតឹងរឹង ដោយតាមប្រធានបទ ឬតាមរយៈយន្តការនៃការអនុញ្ញាត ឬសំណើសុំប្តឹងសាទុក្ខ។ គេធ្វើយុត្តិកម្មលើការកម្រិតទាំងនេះ ដោយមានមូលដ្ឋាននៅលើការពិចារណាអំពីភាពត្រឹមត្រូវ និងការសន្សំសំចៃថវិកាតុលាការៈ ឧទាហរណ៍ ដូចជាថាតើ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាដំណោះស្រាយភ្លាមៗលើ

---

[6] **E169/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២ និងក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, ២៤ ធ្នូ ២០០៩ ត្រង់កថាខ័ណ្ឌទី១០-១២។

[7] វិធាន ១០៤(៤) ។

[8] *ដដែលដូចមុន* ។

[9] សូមអាន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៣៤៣ ។

[10] សូមអាន, ឧទា. ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, មាត្រា៥០៧ ។

[11] សូមអាន, ឧទា. វិធានស្តីពីភស្តុតាង និងនីតិវិធី សម្រាប់តុលាការ ICTY, វិធាន៧២។ វិធានស្តីពីភស្តុតាង និងនីតិវិធី សម្រាប់តុលាការ ICTR, វិធាន៧៣។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, 2187 U.N.T.S. 90 (ចូលជាធរមាននៅថ្ងៃទី០១ កក្កដា ២០០២), មាត្រា៨២ ("ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម")។ វិធានស្តីពីភស្តុតាង និងនីតិវិធី សម្រាប់តុលាការ ICC, វិធាន ១៥៤-១៥៥។

បញ្ហាទាំងនោះ ដោយអង្គជំនុំជម្រះតុលាការកំពូលអាចនឹង "ពន្លឿនកិច្ចដំណើរការនីតិវិធីបានជាក់ស្តែង" ដែរឬទេ[12]។

*តាមវិធាន១០៤(៤)(ឃ) គេគ្មានមូលដ្ឋានផ្លូវច្បាប់សម្រាប់ឲ្យមានការទទួលយកបណ្តឹងសាទុក្ខនេះទេ*

៦. សហមេធាវីការពារក្តីសំអាងបន្ថែមទៀតថា សេចក្តីសម្រេចដែលរងការជំទាស់*ខ្លួនវានេះ* បណ្តាលឲ្យមាន "ការជ្រៀតជ្រែកមួយចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"[13] ដូច្នេះហើយ វាជាប្រធានបទនៃបណ្តឹងសាទុក្ខភ្លាមៗ តាមវិធាន១០៤(៤)(ឃ)។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា វាគ្មានមូលដ្ឋានតាមផ្លូវច្បាប់ណាមួយដែលទំនងជាបានបកស្រាយលើសេចក្តីសម្រេចដែលរងការជំទាស់នេះថាជា "*សេចក្តីសម្រេចមួយ* ស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន៣៥(៦)" នោះឡើយ[14]។ តាមសេចក្តីសម្រេចផ្ទាល់មាត់មួយរបស់ខ្លួនក្នុងនាមអង្គជំនុំជម្រះសាលាដំបូង លោកប្រធានមិនបានធ្វើសេចក្តីយោងទៅដល់វិធាន៣៥ នោះទេ គឺមិនបានយោងទៅដល់ទស្សនៈស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬពីបញ្ហាជាប់ពាក់ព័ន្ធណាមួយ នោះឡើយ។ នៅក្នុងន័យនេះ ការដាក់ជូននានាស្តីពីបណ្តឹងសាទុក្ខគឺ គ្មានអង្គសេចក្តីទាំងស្រុង។

៧. សហមេធាវីការពារក្តី ប៉ុនប៉ងធ្វើឲ្យ អង្គជំនុំជម្រះអនុវត្តវិធាន៣៥ ចំពោះ "អង្គជំនុំជម្រះសាលាដំបូងខ្លួនឯង"[15] - គឺថា ក្នុងឋានៈជាអង្គភាពតុលាការមួយ - ដោយមានមូលដ្ឋានមិនត្រឹមត្រូវមួយដែលថា អង្គភាពចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងកម្រិតណាមួយទៅលើការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយគ្រាន់តែអនុវត្តមុខងារតុលាការដ៏ត្រឹមត្រូវរបស់ខ្លួន និងចេញសេចក្តីសម្រេចដែលរងការជំទាស់នេះ។ ដូចដែលសហមេធាវីការពារក្តីបានទទួលស្គាល់រួចហើយថា គោលជំហរនេះគឺផ្ទុយគ្នាទាំងស្រុងទៅនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ នៅក្នុងការអនុវត្តនូវយុត្តាធិការបន្ទាប់បន្សំរបស់ខ្លួន តាមវិធាន៣៥[16]។ នៅក្នុងករណីនោះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សហមេធាវីការពារក្តីរបស់ អៀង សារី បានដាក់សំណើសុំប្តឹងជិតចិត្ត តាមវិធាន៣៤ ដោយមានមូលដ្ឋាននៅលើការលើកឡើងចោទប្រកាន់ពីអង្គហេតុដូចគ្នានេះដែរ។ អង្គបុរេជំនុំជម្រះបានសម្រេចថា សំណើរបស់សហមេធាវី

---

[12] *ដដែលដូចមុន* ។

[13] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី៨។

[14] វិធាន ១០៤(៤)(ឃ) [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*] ។

[15] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី៨។

[16] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី៨។ សូមអាន សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំប្តឹងជិតចិត្តចៅក្រម Marcel Lemonde តាមវិធាន៣៥, សំណុំរឿងលេខ ០០២/០៧-១២-២០០៩-អវតក/អបជ(០៦), ថ្ងៃទី២៩ មីនា ២០១០ ត្រង់កថាខណ្ឌទី ១១-១៥។

ការពារក្តីតាមវិធាន៣៥ នោះ "គឺជាការប៉ុនប៉ងមួយដើម្បីពង្រីកយុត្តាធិការរបស់ អវតក ដែលត្រូវបានបដិសេធចោល"[17]។

៨. ទាក់ទងនឹងបញ្ហានេះ ចេតនាពិតប្រាកដនៃបណ្តឹងសាទុក្ខបច្ចុប្បន្នមួយនេះ បានលេចចេញច្បាស់រួចហើយ៖ ដោយយល់ឃើញថាវិធាន១០៤ មិនសូវជាស្រួល សហមេធាវីការពារក្តីក៏បានប៉ុនប៉ងម្តងទៀតប្រើប្រាស់វិធាន៣៥ ទាំងខុសឆ្គងដើម្បីលេងកលឧបាយជាលើកទីពីរក្នុងបណ្តឹងសាទុក្ខនេះ។ ចេតនានេះគឺស្តែងចេញមកពីបណ្តឹងសាទុក្ខខ្លួនឯងនេះ៖ "...សំណើដែលបានលើកឡើងមិនស្នើឲ្យដាក់*ទណ្ឌកម្ម* ជាការជួសជុលព្យសនកម្មឡើយ ប៉ុន្តែគ្រាន់តែស្នើឲ្យ*កែប្រែ* កំហុសរបស់ចៅក្រម..."[18]។ ការកែប្រែកំហុសតុលាការដែលបានលើកឡើងចោទប្រកាន់នេះ គឺជា ហេតុផលសម្រាប់ធ្វើយុត្តិកម្មក្នុងការពិនិត្យបណ្តឹងសាទុក្ខឡើងវិញ (is the *raison d'être* of appellate review)។ ដោយទុកដោយឡែកនូវ"កាតព្វកិច្ចការពារក្តី"[19] សហមេធាវីការពារក្តីជាថ្មីម្តងទៀតបានចៀសវាងពីយន្តការដ៏ត្រឹមត្រូវសម្រាប់ការប្តឹងសាទុក្ខ។ ដោយហួសពី "ការការពារក្តីយ៉ាងស្វាហាប់"[20] ការណ៍នេះ បានបំពានលើកិច្ចដំណើរការនីតិវិធី អវតក ហើយវាពិបាកនឹងពិចារណាបានថាមានការចាំបាច់ និងសមស្រប នៅក្នុងកាលៈទេសៈនេះណាស់។

*តាមវិធាន១០៥(២) គេគ្មានមូលដ្ឋានផ្លូវច្បាប់សម្រាប់ឲ្យមានការទទួលយកបណ្តឹងសាទុក្ខនេះទេ*

៩. ចុងបញ្ចប់ សហមេធាវីការពារក្តីបានសំអាងថា បណ្តឹងសាទុក្ខនេះគឺអាចទទួលយកបាន ដោយមានមូលដ្ឋាននៅលើវិធាន១០៥(២) ក៏ប៉ុន្តែមិនបានបង្ហាញថា តើគេមានលទ្ធភាពអាចអានវិធាន១០៥(២) ដោយពន្លាតវិសាលភាពនៃសេចក្តីសម្រេចទាំងនេះឲ្យស្ថិតនៅក្រោមបណ្តឹងសាទុក្ខភ្លាមៗ ដូចដែលបានរៀបរាប់នៅក្នុងវិធាន១០៤(៤) បានដោយរបៀបណានោះឡើយ។

*ផលវិបាកនៃចរិតលក្ខណៈជាក់ស្តែងដែលមិនអាចឲ្យទទួលយកបាននៃបណ្តឹងសាទុក្ខ*

១០. អង្គជំនុំជម្រះ "អាចសំរេច" កំណត់លើបណ្តឹងសាទុក្ខភ្លាមៗដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរនានាតែប៉ុណ្ណោះគត់បានហើយ[21]។ ដោយយល់ឃើញអំពីលក្ខណៈជាក់ស្តែងដែលមិនអាចឲ្យទទួលយកបាននៃបណ្តឹងសាទុក្ខ នឹងដោយផ្អែកលើមូលដ្ឋាននៃការគិតគូរពិចារណាពីភាពឆាប់រហ័ស និងការសន្សំសំចៃថវិការបស់តុលាការនោះ សហព្រះរាជអាជ្ញាមិន

---

[17] *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ១៥។

[18] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី៨ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត* ]។

[19] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី៤៧។

[20] **E130/4/1** បណ្តឹងសាទុក្ខ, *ដដែលដូចមុន* ។

[21] វិធាន១០៩(១) នៃវិធានផ្ទៃក្នុង។

ឃើញមានមូលហេតុអ្វីសំរាប់ឲ្យអង្គជំនុំជម្រះធ្វើយុត្តិកម្មដើម្បីអនុញ្ញាតឲ្យធ្វើសវនាការដោយផ្ទាល់មាត់មួយជាសារធារណៈ ដូចដែលបានស្នើឡើងដោយសហមេធាវីការពារក្តីនោះឡើយ[22]។

១១. សហព្រះរាជអាជ្ញា សង្កេតឃើញថា នៅក្នុងខែមីនាឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់ អៀង សារី បានខំព្យាយាមដាក់នូវបណ្តឹងសាទុក្ខភ្លាមៗដែលគ្មានមូលដ្ឋានត្រឹមត្រូវស្រដៀងគ្នានេះ ចំនួនពីរ[23]។ អង្គជំនុំជម្រះបានធ្វើការសំរេចបញ្ចប់ភ្លាមៗ(disposed of summarily) នូវការខំព្យាយាមទាំងនេះដោយបានធ្វើការណែនាំថា កុំឲ្យសហមេធាវីការពារក្តីដាក់សារណាទាក់ទងនឹងបណ្តឹងសាទុក្ខទាំងនោះមកថែមទៀត[24]។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ អៀង សារី បានដាក់បណ្តឹងសាទុក្ខភ្លាមៗដែលជាក់ស្តែងមិនអាចឲ្យទទួលយកបានមួយមកបន្ថែមទៀត[25] ដោយផ្អែកលើមូលដ្ឋាននៃការពោលអះអាងផ្សេងៗដែលផ្ទុយពីអត្ថន័យដ៏ ច្បាស់លាស់ នឹងពីសេចក្តីបញ្ជាក់អះអាងនៅក្នុងវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង[26]។ សេចក្តីសំរេចលើបណ្តឹងសាទុក្ខក្រោយនេះកំពុងតែស្ថិតក្នុងការរង់ចាំនៅចំពោះមុខអង្គជំនុំជម្រះ។ គំរូជាតួយ៉ាងនៃសារណាលើបណ្តឹងសាទុក្ខដែលគ្មានមូលដ្ឋានត្រឹមត្រូវទាំងនេះ គឺជាការរំលោភលើដំណើរការរឿងក្តីរបស់ អវតក ហើយគឺជាការដាក់បន្ទុកផ្នែកធនធានដែលមានខ្វះខាតស្រាប់និងពេលវេលា ទៅលើអង្គជំនុំជម្រះក៏ដូចជាភាគីនានា។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញា សូមលើកឡើងថាអង្គជំនុំជម្រះគួរតែបញ្ជូនសារណាដែលបានធ្វើឡើងដោយសហមេធាវីការពារក្តីរបស់ អៀង សារី លើបណ្តឹងសាទុក្ខនេះទៅឲ្យអង្គភាពគាំពារការការពារក្តីវិញដើម្បីធ្វើការវាយតម្លៃថា តើសារណានេះមានលក្ខណៈចាំបាច់ហើយព្រមទាំងសមហេតុសមផលផងដែរ ឬទេ?[27]។

---

[22] ឯកសារលេខ **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សំគាល់លេខ១ *ខាងលើ* ត្រង់កថាខណ្ឌទី១៥ និងទំព័រ៣០។

[23] ឯកសារលេខ **E9/7/1/1** សេចក្តីជូនដំណឹងរបស់ អៀង សារី អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថាៈ ការសំរេចបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេលកំណត់ (ឯកសារលេខ E9/7 និងលេខ E9/4/9), ចុះថ្ងៃទី២ មីនា ២០១១។ និងឯកសារលេខ **E51/5/5** សេចក្តីជូនដំណឹងរបស់ អៀង សារី ស្តីពីបណ្តឹងសាទុក្ខប្រឆាំងដីកាបង្គាប់ទៅមេធាវីរបស់ អៀង សារី ស្តីពីការដាក់អញ្ញត្រកម្មបឋម, ចុះថ្ងៃទី៩ មីនា ២០១១។

[24] ឯកសារ **E9/7/1/1/1/4** សេចក្តីសំរេចលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខចំនួនពីរដែលបានដាក់ដោយ អៀង សារី, ចុះថ្ងៃទី៨ មេសា ២០១១ ត្រង់ទំព័រ២ ("[]សេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសហមេធាវីបានមានបំណងចង់ប្តឹងសាទុក្ខប្រឆាំងដូចនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនោះ គឺវាមិនស្ថិតនៅក្នុងរង្វង់នៃយុត្តាធិការដែលមានការកំណត់របស់អង្គជំនុំជម្រះសំរាប់បណ្តឹងសាទុក្ខភ្លាមៗដែលស្ថិតក្រោមវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៧)នោះឡើយ")។

[25] ឯកសារលេខ **E95/8/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាងនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យដកចេញនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ចុះថ្ងៃទី២៦ តុលា ២០១១។

[26] សូមអាន ឯកសារលេខ **E95/8/1/2**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសុំឲ្យដកចេញនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ចុះថ្ងៃទី២ ធ្នូ ២០១១ ត្រកថាខណ្ឌទី៤។

[27] អនុលោមតាមវិធាន១១(២)(ជ) នៃវិធានផ្ទៃក្នុង និងមាត្រា ច១០ នៃសេចក្តីណែនាំស្តីពីគំរោងការជំនួយផ្នែកច្បាប់ដល់ អវតក (Article F10 of the Guide to the ECCC Legal Assistance Scheme)។

១២. អាស្រ័យដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើដោយគោរពដល់អង្គជំនុំជម្រះ សូមមេត្តា៖

(១) ចាត់ទុកថា បណ្តឹងសាទុក្ខនេះទាំងមូល មិនអាចទទួលយកបានឡើយ។

(២) បដិសេធចោលនូវសំណើរបស់សហមេធាវីការពារក្តីដែលស្នើសុំឲ្យធ្វើសវនាការដោយផ្ទាល់មាត់មួយជាសាធារណៈ។

(៣) បញ្ជូនសារណានានាលើបណ្តឹងសាទុក្ខនេះទៅឲ្យអង្គភាពគាំពារការការពារក្តីវិញ ដើម្បីធ្វើការប៉ាន់ប្រមាណវាយតម្លៃមួយអំពីថា តើកិច្ចការដែលបានធ្វើឡើងនោះតើវាមានលក្ខណៈចាំបាច់ ព្រមទាំងសមហេតុសមផលផងដែរ ឬទេ?៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |